# សិលាចារឹកវត្តសិលាចារឹក ហៅវត្តក្តីត្រឹប K.៥១

## ១- ព័ត៌មានទូទៅ

កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តព្រៃវែងបានដឹកនាំមន្ត្រីជំនាញ សហការជាមួយអង្គភាពនគរបាលការពារបេតិកភណ្ឌខេត្ត ព្រមទាំងអាជ្ញាធរដែនដីមូលដ្ឋាន បានចុះពិនិត្យនិងទទួលយកបំណែកសិលាចារឹកមួយពីលោក យា សុវណ្ណា ជាប្រជាពលរដ្ឋរស់នៅភូមិថ្កោល ឃុំបឹងដោល ស្រុកព្រះស្តេច ខេត្តព្រៃវែង យកមករក្សាទុកនៅសារមន្ទីរខេត្តព្រៃវែង[១]។ ព័ត៌មានពីបំណែកសិលាចារឹកនេះទទួលបានពីក្រុមការងាររដ្ឋបាលស្រុកព្រះស្តេច ដែលចុះស្រាវជ្រាវចងក្រងអំពីប្រវត្តិរបស់ស្រុកមួយនេះ និងយបានផ្តល់ដំណឹងមកមន្ទីរវប្បធម៌ខេត្ត។ ក្រោយពី លោក សរ សុផៃ ជាមន្ត្រីការិយាល័យសារមន្ទីរ នៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ទាក់ទងមកដោយបង្ហាញរូបថត ទើបយើងផ្ទៀងផ្ទាត់ទៅដឹងថាជាបំណែកសិលាចារឹក ដែលអ្នកស្រាវជ្រាវបានស្គាល់ពីយូរណាស់មកហើយ ប៉ុន្តែបានបាត់ដានចេញពីទីតាំងដើម។ ទីតាំងដើមនៃសិលាចារឹកនេះ បច្ចុប្បន្នត្រូវនឹងវត្តសិលាចារឹក ហៅវត្តក្តីត្រឹប ស្ថិតនៅក្នុងភូមិព្រាំខ្សាច់ ឃុំល្វា ស្រុកព្រះស្តេច ខេត្តព្រៃវែង។ ដោយសារសិលាចារឹកនេះហើយ ទើបវត្តនេះដាក់ឈ្មោះជាផ្លូវការថា «វត្តសិលាចារឹក»។ សិលាចារឹកនេះរកឃើញដោយលោក លុយណេត៍ ដឺ ឡាហ្សុងគីយែរ៍ នៅវត្តមួយដែលគេបោះបង់ចោលនៅតំបន់បាភ្នំ។ សិលាចារឹកស្ថិតនៅទីនោះរហូតដល់ឆ្នាំ១៩២៣ ទើបមានក្រុមការងារផ្តិតសំណៅឯកសារទុក និងចុះបញ្ជីសារពើភណ្ឌលេខ K.៥១[២]។ បន្ទាប់មកទៀត សិលាចារឹកនេះក៏បានបាត់ចេញពីទីតាំងដើម មិនដឹងតាំងពីពេលណាមក បច្ចុប្បន្នរកឃើញវិញតែផ្នែកខាងក្រោមខាងស្តាំមួយចំហៀងប៉ុណ្ណោះ។

[១] ព័ត៌មានទទួលបានពីលោក សរ សុផៃ និងទំព័រហ្វេសប៊ុកសារមន្ទីរខេត្តព្រៃវែង។

[២] សឺដេស, ១៩៥៣។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ោ សុខវីន

នៅឆ្នាំ១៩៥៣ លោក ហ្ស៊ក សឺដេស បានសិក្សាសិលាចារឹកនេះជាភាសាបារាំង ក្នុងសៀវភៅ សិលាចារឹកនៃប្រទេសកម្ពុជា ក្បាលទី៥។ ក្រោយមកលោក ហ្វីលីព ចេណ្ណឺរ បានសិក្សាតែផ្នែកភាសាខ្មែរនៃសិលាចារឹក បកប្រែជាភាសាអង់គ្លេសនៅក្នុងស្នាដៃរបស់លោក Part xml, № 53 និងចុះផ្សាយនៅគេហទំព័រ http://sealang.net/ok/corpus.htm។

សិលាចារឹក K.៥១ មានកម្ពស់៦៧ស.ម. បន្ទារ៦០ស.ម. និងកម្រាស់៤ស.ម.[៣]។ សិលាចារឹកនេះពុំមានចុះកាលបរិច្ឆេទឡើយ ប៉ុន្តែលោក ហ្ស៊ក សឺដេស បានសន្និដ្ឋានថាប្រហាក់ប្រហែលនឹងសិលាចារឹកក្ដីអង្គ K.៥៤ ដែលចារនៅគ.ស. ៦២៩[៤]។ អត្ថបទចារឹកនេះមានចំនួន១៩បន្ទាត់ ដែល១៧បន្ទាត់ដំបូងចារជាភាសាខ្មែរសម័យមុនអង្គរ និងពីរបន្ទាត់ចុងក្រោយជាភាសាសំស្ក្រឹត។ ស្លោកសំស្ក្រឹតទាំងពីរសរសេរជាប់គ្នារដឹកមិនបែងចែកឃ្លាឡើយ។ ជារួមសិលាចារឹកនេះនិយាយពីតង្វាយរបស់ម្រតាញឥន្ទ្រទត្តដល់ប្រាសាទព្រះគម្ដែងអញស្រីមធុរិបុ[៥] ដាក់រួមផ្សំជាមួយប្រាសាទព្រះគម្ដែងអញ... បុរុសវទស្វាមី និងស្វាមីចតុវិទ្យ... មានអ្នកបម្រើ៤ប្រភេទគឺអ្នករបាំ ផ្លេលើ ចំទក និងអ្នកបម្រើមានតួនាទីធ្វើស្រែព្រមទាំងច្បារដំណាំ និងស្រែ។ ឃ្លាភាសាខ្មែរនិងស្លោកសំស្ក្រឹតបន្ទាប់ពីនោះ គឺជាបណ្ដាសារដល់អ្នកដែលចង់បានតង្វាយរបស់ម្រតាញឥន្ទ្រទត្តឱ្យធ្លាក់នរកទាំង៧សន្ធាន។

លោក សឺដេស (១៩៥៣) យល់ថាម្រតាញឥន្ទ្រទត្ត ថ្វាយតង្វាយដល់ទេពមួយអង្គព្រះនាមព្រះគម្ដែងអញស្រីមធុរិបុ ដោយដាក់រួមផ្សំឧបភោគបរិភោគនឹងប្រាសាទមួយឬច្រើនទៀត។ លោក ចេណ្ណឺរ យល់ដូចនេះដែរ ដោយលោកបាននិយាយថាតង្វាយថ្វាយដល់ទេពព្រះនាមព្រះគម្ដែងអញស្រីមធុរិបុ ដាក់រួមផ្សំឧបភោគបរិភោគជាមួយទេពមួយអង្គដែលបាត់ព្រះនាម (ប.២៖ វ្រះកម្រតាងអញ...) និងបុគ្គលពីររូបទៀត។

ក្នុងសិលាចារឹក K.៦៦ លោក សឺដេស (១៩៤២) យល់ថា «វ្រះកម្រតាងអញគ្រីគាលគ្រាមស្វាមី» ជាម្ចាស់តង្វាយម្នាក់ ដែលជាប្រក្រតីនៅសម័យមុនអង្គរការប្រើប្រាស់

[៣] សឺដេស, ១៩៥៣។

[៤] សឺដេស, ១៩៥៣។

[៥] សឺដេស, ១៩៥៣។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ោ សុខរិន

ឋានន្តរនាមនេះ គឺចំពោះតែព្រះមហាក្សត្រនិងទេពប៉ុណ្ណោះ។ យោលតាមលោកសឺដេស លោក វិកឃើរី (១៩៩៨) ស្នើថា «វ្រះកម្រតាងអញត្រីមធុ...» និងម្រតាញឥន្ទ្រទត្តដាក់ផ្សំគ្រឿងឧបភោគបរិភោគព្រះគម្តែងអញបុរុសវទស្វាមីនិងស្វាមីចាតុរ៌្យ។ ប្រសិនបើដូច្នោះ សេចក្តីនៅបន្ទាត់ទី១៦ដែលនិយាយថា ព្រះគម្តែងអញទាំងពីរ គឺត្រូវនឹងព្រះគម្តែងអញបុរុសវទស្វាមីនិងស្វាមីចាតុរ៌្យ[៦]។ ចំពោះការប្រើឋានន្តរនាម «វ្រះកម្រតាងអញ» វិញ លោក វិកឃើរី ពន្យល់ថាជាការខិតខំរបស់មេដឹកនាំតាមតំបន់ ដើម្បីទទួលបានឋានៈជារាជវង្ស ក្នុងពេលដែលអំណាចមជ្ឈិមចុះខ្សោយ (មុនរជ្ជកាលព្រះបាទស្រីជយវរ្ម័ទី១) ហើយលោកក៏បានស្នើបំពេញអត្ថបទដែលដាច់នៅបន្ទាត់ទី១ ក្នុងសិលាចារឹកនេះជា «វ្រះកម្រតាងអញត្រីមធុរបុរ/ស្វាមី»។ ក្នុងករណីនេះដែរ លោក វិកឃើរី បានកំណត់អាយុកាលសិលាចារឹកនេះ ចារឡើងនៅអំឡុងទសវត្សឆ្នាំ៦៤០ ឬ៦៥០។

យើងសង្កេតឃើញថានៅបន្ទាត់ទី២ បន្ទាប់ពី «វ្រះក» បើទោះបីជាបំពេញបន្ថែមនូវ «ម្រតាងអញ» ហើយក្តី ក៏នៅចន្លោះទំនេរដែលអាចបំពេញបានបួនអក្សរទៀតដែរ[៧] គឺពុំសមនឹងបូកពាក្យ «បុរុបវទស្វាមិ» ថែមឡើយ ពោលគឺ «វ្រះកម្រតាងអញ...» អាចជាព្រះនាមមួយដាច់ពី «បុរុបវទស្វាមិ»។ ឯព្រះគម្តែងអញទាំងពីរដែលនៅបន្ទាត់ទី១៦នោះ អាចសំដៅដល់ព្រះគម្តែងអញស្រីមធុ[រិបុ] និងព្រះគម្តែងអញនៅបន្ទាត់ទី២ដែលបាត់ឈ្មោះនេះ។ ម្យ៉ាងទៀតលោក ចេណ្ណឺរ មិនយល់ស្របជាមួយការប្រែរបស់លោកសឺដេសទាក់ទងនឹង "វ្រះកម្រតាងអញត្រីគាលគ្រាមស្វាមី" នៅក្នុងសិលាចារឹក K.៦៦ ឡើយ ដោយហេតុដូចចដែលបានលើកឡើងហើយថា ការប្រែដូចនោះខ្វាស់នឹងសេចក្តីក្នុងសិលាចារឹកផ្សេងទៀតនៅសម័យនោះ។ ដូចនេះ យើងយល់ស្របតាមលោកសឺដេស និងលោក ចេណ្ណឺរ ដែលយល់ថា ព្រះគម្តែងអញស្រីមធុ[រិបុ] គឺជាទេព និងតាមយោបល់លោក ចេណ្ណឺរ ដែលចែកព្រះនាមទេពជាបួន។

---

[៦] សូមអានការពិភាក្សាពីព្រះនាមទេពទាំងពីរក្នុងអត្ថបទលោក វិកឃើរី ឆ្នាំ១៩៩៨ ទំ.១៥០-១។

[៧] លោក សឺដេស, ១៩៥៣; និងលោក ចេណ្ណឺរ។

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

១- [ជ្រះក]ម្រតាងអញគ្រឹមធុ[[វិបុ]]...[៨][ម្រតាញ]

២- [ឥន្ទ្រទ]ត្តទុកិសំបរិភោគទ្រោងជ្រះក[ម្រតាងអញ]...

៣- បុរុបវទស្វាមិទ្រោងស្វាមិចាតុវ្វិទ្យ...[ក្រុំ][៩]

៤- មនិម្រតាញឥន្ទ្រទត្តឱយរបមិកុស្រេគ...

៥- ...ត១កុកន្ទិនិ១កុអ្កា១កុតីត្តរុ១កុងរិជោរិ១[កុ]...

៦- ...ងបុ១ប្វេលេ។កុហេតិ១កុបោញ១កុឱងនះ១កុ...

៧- ...◌ះ២កុជ្រះហញ១អ្នេវឯតិ១កុវះអជី១កុសាវេត្រិយ១...

៨- កុឃិដុង១កុឃីនោចិចំទកិ។វកុរាកិ១វកញ្ចេង១វអំវិលិ[១]

៩- វបរោយិ១វស្រេចិ១វកន្ទាសិ១វកញិចសិ១វឯកាទគី១វស្អួង[១០][១]

១០- អ្នកិស្រេវត្មិះវស្តៅ១វក្វិ១វជីវទាសិ១វគុណ១វរំ-១វ-១វមេង១

១១- វសង្កាហ្វិ១វបញ្ចមី១វធនករ១វអ្កាកុបី១វត្បញិក្វនិ

១២- វត្រហ្វិ១វកន្ទិនិ១វទគមី១វបិតិ១កុតាង១កុអ្នេអ្កា១កុម្រតាង[១១][១]

១៣- កុបីតងគាយ១កុតេងប្យោរិ១ទំវ្រិង[១២]ព្វទេវសភា១ស្រេព្វ...

១៤- ត្រលាចិ១...បិណ្ឌាក្មុមិជោង៤០-១០-១[គេ][១៣]ជ្រះត្នះកោទ្រ្យសា

១៥- លហិចៅប្រសាលហិកោនិចៅម្រតាញ-លហិអ្នកិមោយិលហិគេតស្វៃរ...

១៦- -ហិវជ្រះកម្រតាងអញតវេរពោហិតគិ◌ុនោះផលមន្ទេ...

១៧- មេធចោត្ត៌មន្តេមាទ្រគិ◌ុ។គេតបំបតិចោត្ត៌មន្តេទៅនរក៕

១៨- ទ្វិជាតេវិន្ទ្រទត្តាខ្យាទ្រូវិណំយន្នុវទ្វិបះតទិច្ឆតិគ្ន្យហីតុំយស្សយាតុន[វកំ]--

---

[៨] លោក ចេណ្ណឹរ ស្នើថា --អំនោយិមនិ។

[៩] ថែមដោយលោក ចេណ្ណឹរ។

[១០] លោក សឺដេស និងលោក ចេណ្ណឹរ អានជា សអង។

[១១] លោក ចេណ្ណឹរ ប្រហែលច្រលំអានជា ម្រតាញ។

[១២] សំណេរត្រឹមត្រូវគួរជា «ទំម្រិង»។

[១៣] ថែមដោយលោក ចេណ្ណឹរ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង និង បៅ សុខរីន

១៩- ឥន្ទ្រទត្តស្យទេវស្វំយោហទ៌មកិវាញ្ចតិ---ន្នរកំយាតុបិត្ងកិស្សប្តជ-ស-

## ៣- អត្ថបទប្រែសម្រួល

(១-៣) (ប្រាសាទ)ព្រះគម្តែងអញស្រីមធុរិបុ... ម្រតាញឥន្ទ្រទត្តទុកផ្សំគ្រឿងឧបភោគបរិភោគជាមួយ(ប្រាសាទ)ព្រះគម្តែងអញ... បុរុសវទេស្វាមី ជាមួយស្វាមីចាតុវ៌ិទ្យ...។

(៣-១៤) អ្នកបម្រើដែលម្រតាញឥន្ទ្រទត្តថ្វាយ(មាន) អ្នករបាំ(ឈ្មោះ)កុស្រេគ...ត១ កុកន្ទិន១ កុអ្កា១ កុតីត្តវុ១ កុងរង៉ោវ១ កុ... ងបុ១, ផ្ទៃលើ(ឈ្មោះ)កុហេត១ កុបោញ១ កុឌងនះ១ កុ... ះ២ កុវ្រះហញ១ ម៉ែវឯត១ កុវះអជី១ កុសាវេត្រិយ១... កុយិជុង១ កុយីនោច, ចំទក(ឈ្មោះ)វកុរាក១ វកញ្ចេង១ វអំពិល១ វបរោយ១ វស្រេច១ វកន្ទាស១ វកញ្ចាស់១ វឯកាទសី១ វស្អង១, អ្នកស្រែ(មាន)វត្និះ វស្តៅ១ វខ្ចី១ វជីវទាស១ វគុណ១ វរំ-១ វ-១ វមេង១ វសង្ការ១ វបញ្ចមី១ វធនករ១ វអ្កាកុបី១ វត្បាញកូន វត្រាវ១ វកន្ទិន១ វទេសមី១ វបិត១ កុតាង១ កុមេតា១ កុម្រតាង១ កុបីតង្កាយ១ កុតេងប្យោរ១ ច្បារទម្រើងនៅឯទេពសភា១ ស្រែនៅឯ...ត្រឡាច១... សរុបអ្នកបម្រើទាំងឡាយ៥១។

(១៤-១៧) អ្នកបម្រើព្រះ កូនប្រសាក្តី ដល់ចៅប្រសាក្តី កូនចៅម្រតាញ-ក្តី អ្នកណាមួយក្តី អ្នកដែលស្ម័គ្រ...ក្តី(ដែល)...ព្រះគម្តែងអញទាំងពីរនោះ ផលដែលធ្វើ...ចូរគេមាន។ អ្នកដែលបំបាត់នូវចោត្តំ(/ពន្ទឹ?) អ្នកនោះនឹងធ្លាក់នរក។

(១៨) នរណាដែលប្រាថ្នាយកពីព្រាហ្មណ៍ឥន្ទ្រទត្ត នូវទ្រព្យ(នៃទេព)ជាសត្រូវនៃអសុរមុរ (គឺព្រះនារាយណ៍) ចូរអ្នកនោះទៅកាន់នរក។

(១៩) នរណាដែលប្រាថ្នាយកទ្រព្យព្រះរបស់ឥន្ទ្រទត្ត ចូរអ្នកនោះទៅកាន់នរកជាមួយនឹងបិតរគណទាំង៧សន្តានរបស់គេ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង និង ប៉ៅ សុខរីន

## ៤- សន្និដ្ឋានរួម

សិលាចារឹកវត្តសិលាចារឹក ហៅវត្តក្ដីត្រឹប K.៥៤១ មានតម្លៃខាងទិដ្ឋភាពនៃការប្រតិបត្តិជំនឿសាសនានៅសម័យមុនអង្គរ។ លើសពីនេះការដែលរកឃើញបំណែកនៃសិលាចារឹកនេះវិញបង្ហាញពីការសហការគ្នារវាងមន្ត្រីជំនាញ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងការថែរក្សាសម្បត្តិវប្បធម៌ជាតិដែលជាគំរូដ៏ល្អមួយ។ ដូច្នេះយើងសូមអំពាវនាវឱ្យប្រជាពលរដ្ឋដែលមានសិលាចារឹក ឬរកឃើញសិលាចារឹក គប្បីជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានដើម្បីយកទៅរក្សាទុកនៅទីតាំងសមស្រប។

## ៥- វាក្យសព្ទ

| | |
|---|---|
| **សំ** | (សំ.) រួម ផ្សំ បញ្ចូល។ |
| **បរិភោគ** | (សំ.) គ្រឿងឧបភោគបរិភោគ។ |
| **ត្រទាង** | ទាំង ជាមួយ។ |
| **របមិ** | > របាំ= អ្នករបាំ។ |
| **ប្ញលេ** | អ្នកបម្រើរ៉ាប់រងការងារនៅវិហារខាងថ្នាក់លើ[១៤]។ |
| **ចំទក** | ឈ្មោះអ្នកបម្រើរ៉ាប់រងកិច្ចការព្រះវិហារ[១៥] សិប្បករ[១៦]។ |
| **ទំព្រង** | ច្បារដំណាំមានទ្រើង។ |
| **ត្នះ** | ណាស់[១៧]។ |
| **ស្វៃរ** | (សំ.) ដែលសេរី មិនមានការបង្ខិតបង្ខំ។ |

[១៤] ឡុង សៀម, ២០០០។

[១៥] ឡុង សៀម, ២០០០។

[១៦] លោក Michael Vickery, 1998 យល់ដូច្នេះតាមការពន្យល់របស់លោក Gérard Diffloth, 1984 លើពាក្យProto-Monic *daac ថា "វាយ, ដំ(ដែក)"។

[១៧] ឡុង សៀម, ២០០០។

# បញ្ជីឯកសារ

ឡុង សៀម. (២០០០). វចនានុក្រមខ្មែរបុរាណ (តាមសិលាចារឹកបុរេអង្គរ សតវត្សទី៦ - ៨). ភ្នំពេញ: រោងពុម្ពភ្នំពេញ.

Cœdès, George. (1942). Inscription de Snày Pol. In *Inscriptions du Cambodge* (Vol. II, pp. 51-3). Paris: Editions de Boccard.

Cœdès, George. (1953). Inscription de Vằt Kdĕi Trằp. In *Inscriptions du Cambodge* (Vol. V, pp. 14-16). Paris: Editions de Boccard

Diffloth, Gérard. (1984). *The Dvaravati Old Mon Language and Nyah Kur*. Monic Language Studies I. Bangkok: Chulalongkorn University Printing House, 1984.

Vickery, Michael. (1998). *Society, Economics, and Politics in pre-Angkor Cambodia*. The Centre for East Asian Cultural Studies for UNESCO, The Tokyo Bunko.

## គេហទំព័រ

http://sealang.net/ok/corpus.htm

https://ams.com.kh/khmercivilization/detail/28234

# បញ្ជីរូបភាព



n. 727 / K. 51

សំណៅសិលាចារឹកវត្តសិលាចារឹក ហៅវត្តក្ដីត្រឹប K.៥១ (រូបថត៖ EFEO តាមរយៈ CISARK )

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ោ សុខរីន



បំណែកសិលាចារឹក រកឃើញនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ (រូបថត៖ សរ សុផៃ)



សកម្មភាពប្រគល់ទទួលបំណែកសិលាចារឹកជូនមន្ទីរវប្បធម៌ខេត្តព្រៃវែង

(រូបថត៖ សារមន្ទីរខេត្តព្រៃវែង)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ោ សុខរីន